ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ

# សេចក្តីប្រកាសព័ត៌មាន

## ស្តីពី

## លទ្ធផលនៃកិច្ចប្រជុំគណៈកម្មការប្រឹក្សាការងារ(LAC) អាណត្តិទី៨ លើកទី១៤

កាលពីរសៀលថ្ងៃទី២៧ ខែកក្កដា ឆ្នាំ២០១៦ នៅទីស្តីការក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ មានបើកកិច្ចប្រជុំគណៈកម្មការប្រឹក្សាការងារអាណត្តិទី៨ លើកទី១៤ ដើម្បីចាប់ផ្តើមជាផ្លូវការនូវការពិភាក្សាអំពីប្រាក់ឈ្នួលអប្បបរមាផ្នែកវាយនភណ្ឌ កាត់ដេរ និងផលិតស្បែកជើង សម្រាប់ឆ្នាំ២០១៧។ តាមរយៈការពិភាក្សារបស់សមាជិកគណៈកម្មការប្រឹក្សាការងារមកពីភាគីទាំង៣ គឺភាគីកម្មករនិយោជិត ភាគីនិយោជក និងភាគីរាជរដ្ឋាភិបាល កិច្ចប្រជុំបានសម្រេចបាននូវលទ្ធផលដូចខាងក្រោម៖

១. ទទួលដឹងឮជាផ្លូវការអំពីការចាប់ផ្តើមការចរចារប្រាក់ឈ្នួលអប្បបរមាផ្នែកវាយនភណ្ឌ កាត់ដេរ និងផលិតស្បែកជើងសម្រាប់ឆ្នាំ២០១៧។

២. បង្កើតក្រុមការងារបច្ចេកទេសត្រីភាគី ដែលមានសមាភាពចំនួន១៦រូបមកពីភាគីនីមួយៗ ដើម្បីពិភាក្សាការងារបច្ចេកទេសក្នុងការកំណត់ប្រាក់ឈ្នួលអប្បបរមា។

៣. ប្រើប្រាស់លក្ខណវិនិច្ឆ័យបែបសង្គម (ស្ថានភាពគ្រួសារ អត្រាអតិផរណា និងការចំណាយក្នុងការរស់នៅ) និងលក្ខណវិនិច្ឆ័យបែបសេដ្ឋកិច្ច (ផលិតភាព ភាពប្រកួតប្រជែងរបស់ប្រទេស ស្ថានភាពទីផ្សារការងារ និងកម្រិតចំណេញរបស់វិស័យ) ធ្វើជាមូលដ្ឋានសិក្សាស្រាវជ្រាវ និងពិភាក្សា និងលើកជាអនុសាសន៍ដល់គណៈកម្មការប្រឹក្សាការងារពិនិត្យសម្រេច។

៤. ប្រើប្រាស់ប្រតិទិនការងារដែលបានកំណត់នាពេលកន្លងមកជាមូលដ្ឋានក្នុងការជួបប្រជុំជាលក្ខណផ្ទៃក្នុងភាគី ទ្វេភាគី និងត្រីភាគី។

សេចក្តីដូចបានជម្រាបជូនខាងលើ សូមសាធារណជន កម្មករនិយោជិត និយោជក អង្គការវិជ្ជាជីវៈ អង្គការជាតិ និងអន្តរជាតិ មេត្តាជ្រាបជាព័ត៌មានតាមការគួរ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី២៧ ខែកក្កដា ឆ្នាំ២០១៦